

# យន្តហោះក្រដាសដ៏អស្ចារ្យ

The Asia Foundation - Let's Read

Yam Luy Chhuy

Let's Read

The Asia Foundation



ថ្ងៃនេះ វេហា ភ្ញាក់ពីព្រឹក រួចសំឡឹងមើលទៅក្រៅបង្អួច។ ផ្ទៃមេឃខៀវស្រងាត់ ខ្យល់ក៏ស្ងប់ល្អ។ ធាតុអាកាសបែបនេះ គឺល្អណាស់សម្រាប់ការហោះហើរ! វេហា និងអក្ខរាដែលជាមិត្តរបស់គេ បានសាកល្បងបង្ហោះយន្តហោះក្រដាសពេញមួយសប្ដាហ៍ហើយ។ ពួកគេបានបង្កើតយន្តហោះក្រដាសដ៏ល្អមួយសម្រាប់ការប្រកួតនៅថ្ងៃនេះ!



វេហា ផ្លាស់អាវគេងយប់ដែលមានរូបយន្តហោះ រួចពាក់អាវក្រណាត់វិញ ប៉ុន្តែអាវនេះក៏មានរូបយន្តហោះដែរ។ វេហា លោតរំលងយន្តហោះគំរូតូចៗដែលនៅរាយប៉ាយក្នុងបន្ទប់របស់គេ ហើយលូកយកច្រាសដុសធ្មេញរូបយន្តហោះមកដុស រួចក៏ដើរសំដៅទៅផ្ទះបាយ។



ម៉ាក់វេហា យាត់៖ «វេហា ញ៉ាំយឺតៗកូន។ កូនញ៉ាំលឿនពេក ហើយ។» មិនខ្វល់នឹងសម្ដីដាស់តឿនរបស់ម៉ាក់គេឡើយ វេហា ដួសបាយពេញមួយស្លាបព្រាទៀត រួចពមចូលក្នុងមាត់។ «ម៉ាក់! ខ្ញុំប្រញាប់ទៅជួប អក្ខរា នៅសាលា។ ខ្ញុំចង់ទៅសាលាពីព្រឹក ដើម្បីមើលអ្នកផ្សេងទៀតធ្វើយន្តហោះ។ យើងត្រូវតែឈ្នះ ការប្រកួតនេះ ដើម្បីអាចទៅលេងព្រលានយន្តហោះ និង ចូលក្នុងយន្តហោះបាន!»



ម៉ាក់វេហា ដកដង្ហើមធំ រួចនិយាយថា៖ «យឺតៗក៏បានដែរកូន។ កុំភ្លេចណា! ពូបូរី ក៏ទៅសាលាកូនដែរ។» ពូបូរី ជាអ្នកដែលជំរុញចិត្តឱ្យ វេហា ស្រឡាញ់យន្តហោះខ្លាំង។ គាត់ជាអ្នកបើកយន្តហោះ។ គាត់បានប្រាប់រឿងរ៉ាវដ៏វែងអន្លាយដល់ វេហា ស្តីពីដំណើរផ្សងព្រេងរបស់គាត់នៅក្នុងបន្ទប់បើកយន្តហោះ និងការធ្វើដំណើរទៅកាន់ទីកន្លែងឆ្ងាយៗ។ វេហាគិតថា ពូរបស់ខ្លួនមានការងារដ៏ល្អបំផុតលើពិភពលោកនេះ។



«ខ្ញុំដឹងហើយម៉ាក់!» វេហា ស្រែកប្រាប់ម្ដាយ នៅពេលដែលគេដើរយ៉ាងប្រញាប់ប្រញាល់ចេញពីផ្ទះ ហើយទុករបស់របររាយប៉ាយពេញលើតុ។ វេហា មិនអាចយឺតបានទេ ព្រោះគេត្រូវប្រាប់ អក្ខរា ថាវាជាថ្ងៃដ៏ល្អបំផុតសម្រាប់ការបង្ហោះយន្តហោះចំបាំងធ្វើពីក្រដាសដែលមានស្លាបខ្លី ហើយលឿនដូចផ្លេកបន្ទោររបស់ពួកគេ។



ប៉ុន្តែនៅពេល វេហា ទៅដល់សាលា អក្ខរាបែរជាមានគំនិតផ្សេងមួយ ទៀត។ អក្ខរា និយាយថា៖ «វេហា! ធាតុអាកាសនេះគឺល្អបំផុតសម្រាប់ ប្រភេទយន្តហោះស្លាបវែងរបស់យើង។ វានឹងហោះពាសពេញទីវាលនេះយ៉ាងអស្ចារ្យ។» វេហា ជ្រួញចិញ្ចើមហើយតបវិញថា៖ «អត់ទេ! យើងត្រូវបង្ហោះយន្តហោះចំបាំងស្លាបខ្លីរបស់យើង។»



អក្ខរា ប្រញាប់និយាយ៖ «ប៉ុន្តែ...» មិនទាន់បាននិយាយអ្វីផង វេហា ក៏និយាយកាត់អក្ខរា៖ «ខ្ញុំយល់ថា យន្តហោះស្លាបវែង មិនឡូយទេ» អក្ខរា សម្លឹងមុខវេហាហើយស្រែកតបវិញ៖ «ហ៊ឹះ! ឯងមិនដែលស្តាប់គំនិតខ្ញុំសោះ។ ខ្ញុំឈប់ធ្វើជាមួយឯងហើយ!» អក្ខរា និយាយ រួចក៏ដើរចេញ។ «ក៏បាន! ឈប់ក៏ឈប់ទៅ។ ខ្ញុំក៏លែងត្រូវការឯងដែរ។»



រំពេចនោះ មានសំឡេងមួយស្រែកសួរវេហា៖ «វេហា! ក្មួយយ៉ាងម៉េចហើយ?» ពូបូរី ដើរមកជិតវេហា ក្នុងឯកសណ្ឋាន និងមួកអ្នកបើកយន្តហោះ រួចនិយាយ៖ «ហេតុអ្វីបានជាទឹកមុខក្មួយរបស់ពូ មិនរីករាយដូចខ្វីចឹង?» វេហា តបទៅកាន់ពូរបស់គេ៖ «អក្ខរា ចង់បត់យន្តហោះស្លាបវែង ជំនួសឱ្យយន្តហោះចំបាំងស្លាបខ្លី។ ពេលនេះ វាឈប់ធ្វើយន្តហោះជាមួយខ្ញុំហើយ។ ថ្ងៃនេះគ្មានបានលទ្ធផលអីទាំងអស់! ខ្ញុំប្រហែលជាគ្មានឱកាសចូលក្នុងព្រលានយន្តហោះ ឬបង្ហោះយន្តហោះអីទេ។»



ពូបូរី សម្លឹងមើលមុខវេហា ហើយញញឹមបន្តិចៈ «អូ! មិនអីទេ។ ក្មួយដឹងទេ រឿងទីមួយដែលអ្នកបើកបរយន្តហោះត្រូវធ្វើ គឺការតាំងអារម្មណ៍នឹងនរ។ គ្រប់យ៉ាងសុទ្ធតែមានដំណោះស្រាយ។ ក្មួយត្រូវរិះរកវិធីដោះស្រាយបញ្ហានេះ។ វេហា ដកដង្ហើមវែង រួចតបៈ «បាទពូ»



ពូ បូរី និយាយទៀតថា៖ «ក្រៅពីនេះ អ្នកបើកយន្តហោះត្រូវតែចេះសម្របខ្លួនធ្វើការជាក្រុម ។ តើក្មួយមានស្តាប់គំនិតរបស់ អក្ខរា ទេ? តើក្មួយមានគិតពីអារម្មណ៍របស់ អក្ខរា ទេ? វេហា និយាយយឺត៖ «ខ្ញុំបាននិយាយកាត់សម្ដីអក្ខរា និងមិនបានផ្តល់ឱកាសឱ្យវាបញ្ចេញគំនិតទេ។ ខ្ញុំក៏មានអារម្មណ៍មិនសូវល្អដែរ។» «តោះយើងទៅរក អក្ខរា ឥឡូវនេះទៅ។»



វេហា ដើររក អក្ខរា និងសុំអភ័យទោសដែលមិនស្ដាប់គំនិតរបស់ អក្ខរា។ វេហា នៅតែចង់សហការជាមួយ អក្ខរា ហើយ អក្ខរា ក៏ចង់សហការជាមួយ វេហា វិញដែរ។



វេហា សួរពូបូរី ថា៖ «អ៊ីចឹងតើយើងគួរសម្រេចថាយកយន្តហោះប្រភេទណា?» ពូបូរី តប៖ «អ្នកបើកយន្តហោះត្រូវដឹងពីស្ថានភាពធាតុអាកាសជានិច្ច រួចទើបកែសម្រួលផែនការរបស់ខ្លួនតាមកាលទេស។» អក្ខរា និយាយថា៖ «យន្តហោះស្លាបធំវែង អាចហោះត្រដាងស្លាបបានខ្ពស់។ ឯងចាំទេ នេះគឺជាអ្វីដែលយើងធ្លាប់បានរៀន។ វាជាវិធីដែលធ្វើឱ្យយន្តហោះនៅលើអាកាសបាន។»



វេហា បន្ថែម៖ «ហើយដោយសារតែថ្ងៃនេះខ្យល់ស្ងប់ល្អ យន្តហោះស្លាបធំវែងនឹងហោះមិនងាយធ្លាក់ដីទេ។» ពួកគេងក់ក្បាលដាក់គ្នា។ វេហា និងអក្ខរា រត់ទៅតុដើម្បីបត់យន្តហោះស្លាបធំវែង។



វេហា សួរទៅពូបូរី៖ «តើពូយល់យ៉ាងណាដែរ?» ពូបូរី តប៖ «យន្តហោះនេះគួរតែអាចហោះបានហើយ! ប៉ុន្តែ អ្នកបើកយន្តហោះត្រូវចំណាយពេលគិតគូរ និងអនុវត្តឱ្យបាន ល្អិតល្អន់ ជាពិសេសលើចំនុចលម្អិតនានា។» បន្ទាប់ពីពិនិត្យ យន្តហោះរួច អក្ខរា និយាយថា៖ «យើងគួរបត់ស្លាបដោយ ផ្ចិតផ្ចង់ជាងនេះ។»



សំឡេងប្រកាសបន្លឺឡើង៖ «សល់ដប់នាទីទៀត ការបង្ហោះយន្តហោះនឹងចាប់ផ្ដើម!» ពូបូរី និយាយថា៖ «ក្មួយៗមានពេលច្រើនទៀត។ ក្មួយត្រូវតាំងចិត្តឱ្យស្ងប់ សហការគ្នា និងយកចិត្តទុកដាក់ឱ្យលើចំនុចលម្អិត។»



ពីរបីនាទីក្រោយមក វេហា បានឈានជើងទៅកាន់ខ្សែបន្ទាត់គប់យន្តហោះដោយអារម្មណ៍តឹងតែង។ យន្តហោះក្រដាសផ្សេងៗទៀតបានធ្លាក់ចុះនៅរាយប៉ាយពេញដី! វេហា ងាកទៅអក្ខរា ហើយនិយាយ៖ «អក្ខរា! ឯងពូកែគប់ណាស់។ តើឯងចង់បង្ហោះយន្តហោះរបស់ពួកយើងទេ?» អក្ខរា តបដោយញញឹម៖ «បានសម្លាញ់!»



ដំបូង យន្តហោះស្លាបធំវែង ហោះខ្ពស់ក្នុងអាកាស រួចដាំក្បាលចុះមកដី ប៉ុន្តែខ្យល់បក់ប៉ះស្លាបដ៏វែងរបស់វា ក៏ធ្វើឱ្យយន្តហោះនោះនៅតែហោះលើអាកាសដដែល។ មហាជនហ៊ោរកញ្ជ្រៀវនៅពេលដែលឃើញយន្តហោះគ្មានមនុស្សបើកនោះនៅតែបន្តហោះទៅមុខ រហូតផុតពីទីវាល!



វេហា និងអក្ខរា អបអរគ្នាទៅវិញទៅមក។ វេហា និយាយថា៖ «គប់បានល្អណាស់ សម្លាញ់! ឯងធ្វើបានជោគជ័យហើយ!» អក្ខរា តប៖ «យើងទាំងពីរធ្វើបានជោគជ័យហើយ! យន្តហោះរបស់យើងគឺល្អជាងគេ! ពូបូរី បន្ថែមទៀតថា៖ «ហើយក្មួយៗនឹងអាចក្លាយជាអ្នកបើកយន្តហោះដ៏អស្ចារ្យនៅថ្ងៃណាមួយមិនខាន។»

Generously supported by Smart Axiata

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*យន្តហោះក្រដាសដ៏អស្ចារ្យ (The Best Paper Plane)*, Author: The Asia Foundation - Let's Read. Illustrator: Yam Luy Chhuy. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/